ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និងឈ្មោះសំណុំរឿង : ០៤/០៨—ខេមបូឌា អ៊ីបភែរ៉ែល

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០៨

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ស៊ីន តឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

ក- ភាគីនិយោជក

**ឈ្មោះ : ក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉ែល អ៊ីនដឹសទ្រី (ក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉ែល)**

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤,ភូមិចំបក់, ឃុំវល្លិស, ស្រុកសំរោងទង, ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ : ០១៦ ៨៦៦ ០៨៩ ទូរសារលេខ : គ្មាន

**តំណាងភាគីនិយោជក :**

១-លោកស្រី អ៊ុន ហ៊ាង រដ្ឋបាលក្រុមហ៊ុន

ខ- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធសហជីពយុវជនខ្មែរ និង សហជីពយុវជនខ្មែរ**

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤,ភូមិចំបក់, ឃុំវល្លិស, ស្រុកសំរោងទង, ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ : ០៩២ ៩០២ ៥៦៩

តំណាងកម្មករនិយោជិត : អវត្តមាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

# បញ្ហាវិវាទ

(ក្នុងរបាយការណ៍មិនសះជា)

១-សុំឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពយុវជនខ្មែរ ដែលមាឈ្មោះ អ៊ុន ម៉ានី. ហួន ផានី. និង កៅ ធា ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ចូលបំរើការងារជាធម្មតាវិញ។

២-សុំឱ្យក្រុមហ៊ុនចាត់វិធានការតាមផ្លូវច្បាប់ ចំពោះប្រធានរដ្ឋបាលឈ្មោះ អ៊ុន ហៀង ដែលរើសកម្មករចូលធ្វើការ យកប្រាក់ពីកម្មករក្នុងម្នាក់ ៣០ ដុល្លារ និងថ្លៃធ្វើកាត ១០ ដុល្លារ នឹងទូទាត់សងកម្មករវិញ។

៣-សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានពេទ្យប្រចាំការនៅក្នុងក្រុមហ៊ុនជារៀងរាល់ម៉ោងធ្វើការ និងមានថ្នាំពេទ្យគ្រប់គ្រាន់។

៤-សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ជូនកម្មករនៅពេលមានជំងឺ មានលិខិតបញ្ជាក់ពីលោកគ្រូពេទ្យរដ្ឋត្រឹមត្រូវ។

៥-សុំឱ្យក្រុមហ៊ុនបញ្ចូលកម្មករដែលធ្វើការសាកល្បង ចាប់ពីពីរខែឡើងទៅ ជាកម្មករពេញសិទ្ធិ និងផ្តល់អត្ថប្រយោជន៍ផ្សេងៗតាមច្បាប់ស្តីពីការងារ។

៦-សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលកម្មករនៅថ្ងៃទី ៥ ជារៀងរាល់ខែនៃខែបន្ទាប់ ឱ្យបានរួចរាល់នៅម៉ោង ៤:០០។

៧-សុំឱ្យក្រុមហ៊ុនចាត់វិធានការចំពោះក្រុមចិនឈ្មោះ លី ឡុងឃី ដែលតែងតែជេរប្រមាថមកលើកម្មករ។

៨-នៅពេលក្រុមហ៊ុនធ្វើកិច្ចសន្យាការងារជូនកម្មករ សុំឱ្យក្រុមហ៊ុនផ្តល់ឱ្យកម្មករមួយច្បាប់ និងនៅពេលបញ្ចប់កិច្ចសន្យា សុំឱ្យទូទាត់ប្រាក់បំណាច់ផ្សេងៗ តាមច្បាប់ស្តីពីការងារ (ទូទាត់រំលឹកសាឡើងវិញ)។

៩-សុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូននៅក្នុងក្រុមហ៊ុន បើក្រុមហ៊ុនពុំមានលទ្ធភាពសង់ទេ សុំប្តូរជាម្សៅទឹកដោះគោ១ខែ បីកំប៉ុង ១កំប៉ុង ១.៥-គីឡូ និងថ្លៃអ្នកថែទាំចំនួន ២៥ ដុល្លារ ក្នុងមួយខែ។

១០-សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពីសហជីពយុវជនខ្មែរក្នុងម្នាក់ ១០០០រៀល ជូនសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ខេមបូឌា អឹបភែរ៉េល។

១១-សុំឱ្យក្រុមហ៊ុនអនុវត្តការធ្វើការថែមម៉ោងផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ។

១២-សុំឱ្យក្រុមហ៊ុនអនុវត្តការឈប់សំរាកពិសេសដល់កម្មករនៅពេលមានធុរៈ។

១៣-សុំកុំឱ្យក្រុមហ៊ុនធ្វើការព្រមានកម្មករនៅពេលម៉ាស៊ីនខូច ឬដេរមិនគ្រប់ចំនួន។

១៤-នៅពេលក្រុមហ៊ុនស្នើសុំឱ្យកម្មករធ្វើការបន្ថែមម៉ោង លើសពីពីរម៉ោង សុំឱ្យក្រុមហ៊ុនដឹកជញ្ជូនកម្មករដល់លំនៅដ្ឋាន។

THE ARBITRATION COUNCIL

១៥-នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ ឱ្យកម្មករឈប់សំរាក សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលពេញ ( ទូទាត់វំលឹកសាឡើងវិញ ) ។

១៦-សុំឱ្យទូទាត់សងនូវរាល់ការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករ ដែលក្រុមហ៊ុនធ្វើការកាត់កងជាមួយនឹងពេលគ្មានការងារឱ្យកម្មករធ្វើកន្លងមក ។

១៧-សុំកុំឱ្យក្រុមហ៊ុនធ្វើការកាត់ប្រាក់ឈ្នួលកម្មករនៅពេលកម្មករបាត់កាត ហើយឱ្យក្រុមហ៊ុនធ្វើក្នុងម្នាក់ ៥០០០ រៀល និងទូទាត់វំលឹកសាឡើងវិញ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) ( មាត្រា ៣០៩ ដល់ ៣១៧ ) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកប.វ./ប្រក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០០៧ ( អាណត្តិទី៥ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ ( ក ) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០០៥ ក.ប.វ/ក.ស្ក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ ។

## នីតិវិធីមុនសវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងកិច្ចប្រជុំមុនសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ "A" វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទនៃកិច្ចប្រជុំមុនសវនាការ :** ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ( វេលាម៉ោង ០៨:៣០ នាទី ដល់ម៉ោង ១០:០០ នាទី ) ។

**បញ្ហានៃនីតិវិធី :**

ក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉េល មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ ៤.ភូមិចំបក់. ឃុំវល្លិស. ស្រុកសំរោងទង. ខេត្តកំពង់ស្ពឺ មានចំនួនកម្មករនិយោជិតចំនួន ៦៧៥ នាក់ ។

យោងតាមរបាយការណ៍មិនសះជា របស់ក្រសួងការងារដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០៨ វេលាព្រឹកព្រលឹម មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានទទួលដំណឹង

ថា មានកម្មករនិយោជិតធ្វើកូដកម្មទាមទារលើលក្ខខណ្ឌការងារនៅក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉េល។ ពេលទទួលបានព័ត៌មានដូចនេះ លោកប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានបញ្ជាឱ្យក្រុមមន្ត្រីជំនាញចុះធ្វើការសាកសួរទៅតាមនីតិវិធីភ្លាមៗ ក្រោយពីការសាកសួរព័ត៌មានពីនិយោជករួច មន្ត្រីជំនាញបានព្យាយាមពន្យល់ណែនាំដល់កម្មករនិយោជិត និងក្រុមហ៊ុនឱ្យមានការយោគយល់អធ្យាស្រ័យគ្នា ហើយធ្វើការដោះស្រាយរឿងនេះ ដោយសន្តិវិធី។ ការព្យាយាមពន្យល់នេះមានរយៈពេលរហូតដល់ម៉ោង១០:៣០នាទីព្រឹក ប៉ុន្តែមិនមានលទ្ធផលនោះទេ។ មន្ត្រីជំនាញក៏បានត្រឡប់មកមន្ទីរការងារវិញ ដើម្បីរកវិធីដោះស្រាយ លុះដល់ម៉ោង ៩:២៥ ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០០៨ មន្ទីរការងារបានទទួលពាក្យបណ្តឹងមួយស្តីពីសំណើរជួយដោះស្រាយនូវការទាមទាររបស់កម្មករ កម្មការិនី នៅក្រុមហ៊ុនកាត់ដេរ ខេមបូឌា អ៊ីបភែរ៉េល។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះហើយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានធ្វើលិខិតអញ្ជើញភាគីក្រុមហ៊ុន សហជីព និងតំណាងកម្មករ កម្មការិនី មកដោះស្រាយនៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨ វេលាម៉ោង៨:៣០ នាទីព្រឹក ក្នុងសំណូមពរទាំង១៧ចំណុច ប៉ុន្តែការផ្សះផ្សានោះពុំបានទទួលលទ្ធផលសះជាទេ ដោយភាគីខាងក្រុមហ៊ុនមិនបានមកតាមការអញ្ជើញនោះទេ ចំណែកតំណាងភាគីកម្មករនិយោជិតក៏មិនព្រមដោះស្រាយដែរ បើគ្មានភាគីខាងក្រុមហ៊ុននោះ។ ដូចនេះ មន្ទីរការងារ និង មន្ត្រីជំនាញបានសំរេចចិត្ត ធ្វើលិខិតអញ្ជើញភាគីជាលើកទីពីរ គឺនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨ដដែល ប៉ុន្តែ គឺនៅម៉ោង២រសៀលវិញ។

នៅថ្ងៃដដែល រហូតដល់ម៉ោង២:៣០ រសៀល ភាគីទាំងពីរមិនបានមកដោះស្រាយនៅមន្ទីរការងារទេ។ ដូចនេះ អ្នកផ្សះផ្សាសំរេចចិត្តបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើសេចក្តីសំរេច ដើម្បីឱ្យការងារនេះបានសម្រេចទាន់ពេលវេលា។

ផ្អែកលើរបាយការណ៍មិនសះជារបស់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ចំណុចវិវាទនៅក្នុងសំណុំរឿងនេះមាន ១៧ចំណុច។ របាយការណ៍មិនសះជានេះត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែមករា ឆ្នាំ ២០០៨។ នៅថ្ងៃដដែលនេះ លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានពីមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ និងពីភាគីនិយោជកថា ភាគីកម្មករកំពុងធ្វើកូដកម្ម។ ស្របពេលជាមួយគ្នានេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏កំពុងតែដោះស្រាយ សំណុំរឿងលេខ ០២/០៨-ខេមបូឌា អ៊ីបភែរ៉េល ដែលជាសំណុំរឿងរវាងភាគីទាំងពីរដែរ គឺភាគីនិយោជករោងចក្រ ខេមបូឌា អ៊ីបភែរ៉េល និង សហជីពយុវជនខ្មែរ។ ចំណុចវិវាទមួយចំនួននៅក្នុងសំណុំរឿងលេខ០២/០៨-ខេមបូឌា អ៊ីបភែរ៉េល ជាចំណុចវិវាទដូចគ្នាទៅនឹងចំណុចវិវាទនៅក្នុងសំណុំរឿង០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល នេះ។ នៅក្នុងសំណុំរឿងលេខ០២/០៨-ខេមបូឌា អ៊ីបភែរ៉េល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ នៅថ្ងៃទី១៥

THE ARBITRATION COUNCIL

ខែមករា ឆ្នាំ២០០៨ ដោយសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល ដោយសារតែភាគីទាំងសងខាងនៅបន្តវិធានការកូដកម្ម និង ឡុកអៅ ក្នុងកំឡុង ពេលនីតិវិធីអាជ្ញាកណ្តាល ។

ក្នុងការដោះស្រាយសំណុំរឿងលេខ០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបង្គាប់ឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញគូរភាគីទាំងពីរ មកចូលរួមក្នុងកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានអញ្ជើញភាគីនិយោជក និង ភាគីសហជីព កម្មករនិយោជិត មកចូលរួមក្នុងកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ វេលាម៉ោង៨:០០ ព្រឹក ដោយបញ្ជាក់ថាក្រុមប្រឹក្សាអាជ្ញាកណ្តាលមានគោលបំណងសាកសួរលើស្ថានភាពកូដកម្ម ឬឡុកអៅ និង ដើម្បីបញ្ជាក់ទៅគូរភាគីថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដំណើរការនីតិវិធីអាជ្ញាកណ្តាលដោះស្រាយវិវាទការងារនេះបាន លុះត្រាតែ ភាគីផ្អាកវិធានការកូដកម្ម ឬឡុកអៅ និង វិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរថែមទៀត ក្នុងកំឡុងពេលដំណើរការអាជ្ញាកណ្តាលនេះ ។ ភាគីនិយោជកបានទទួលការអញ្ជើញមកចូលរួមកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ។ ដោយឡែក នៅពេលភាគីសហជីពទទួលព័ត៌មានអំពីការអញ្ជើញមកចូលរួមកិច្ចប្រជុំមុនសវនាការនេះ ភាគីសហជីពបានបញ្ជាក់មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីសហជីព នឹងមិនមកចូលរួមកិច្ចប្រជុំនេះទេ ដោយលើកហេតុផលថា ការធ្វើដំណើរពីខេត្តកំពង់ស្ពឺមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅភ្នំពេញឆ្ងាយពេក ហើយត្រូវចំណាយច្រើនចំពោះការធ្វើដំណើរ ។ ភាគីសហជីពក៏បានបញ្ជាក់ថា សហជីពកំពុងតែដាក់ពាក្យទៅតុលាការខេត្តកំពង់ស្ពឺ ដើម្បីដោះស្រាយសំណុំរឿងវិវាទការងារនេះ ។ ភាគីសហជីព ក៏បានបញ្ជាក់ថា សហជីពបានមកចូលរួមកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿង លេខ០២/០៨-ខេមបូឌា អ៊ីបភែរ៉េល ថ្មីៗនេះរួចមកហើយៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានអំណាចក្នុងការបញ្ជាឱ្យក្រុមហ៊ុន អនុញ្ញាតិឱ្យកម្មករទាំងអស់ចូលធ្វើការទេ។ ដូច្នេះ សហជីពទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច សំណុំរឿង លេខ០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល តាមនីតិវិធីចុះ ។

នៅក្នុងកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ភាគីនិយោជកមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ ។ ចំណែកឯភាគីសហជីពមិនមានវត្តមាននៅក្នុងកិច្ចប្រជុំនេះទេ ទោះបីជាលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរសព្ទរំលឹកអំពីកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ ។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចសាកសួរព័ត៌មានលំអិតពីភាគីទាំងសងខាងទាក់ទងទៅនឹង សំណុំរឿងលេខ០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល នេះបានទេ ។

រហូតមកដល់ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមករា ឆ្នាំ២០០៨ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីទាំងពីរថា កម្មករនិយោជិតមិនត្រឡប់ចូលធ្វើការទេ គឺនៅតែបន្តការធ្វើកូដកម្មដដែលព្រោះនិយោជកមិនអនុញ្ញាតិឱ្យថ្នាក់ដឹកនាំសហជីព ៣នាក់ចូលធ្វើការវិញ ។

ហេតុនេះហើយ នៅក្នុងរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោមៈ

## ឯកសារ ទស្សនាទ ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :** គ្មាន

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :** គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ខេមបូឌា អ៊ីបកែរ៉េល លេខ ០០៥ ក.ប.វ/ក.ស្ក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨

២-កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេមបូឌា អ៊ីបកែរ៉េល ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១-លិខិតអញ្ជើញភាគីកម្មករនិយោជិត នៃក្រុមហ៊ុនកាត់ដេរ ខេមបូឌា អ៊ីបកែរ៉េល ចូលរួមផ្តល់ពតិមាន លេខ ០៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨

២- លិខិតអញ្ជើញនាយកក្រុមហ៊ុនកាត់ដេរ ខេមបូឌា អ៊ីបកែរ៉េល ចូលរួមផ្តល់ពតិមាន លេខ ០៦០ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨

## ការរកឃើញអង្គហេតុ:

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែល ក្រសួងការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន ។

## ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល ក្នុងសំណុំរឿងលេខ ០៤/០៧-ខេមបូឌា អ៊ីបកែរ៉េល ទេ ដោយសារហេតុផលដូចខាងក្រោម :

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា:

*"ក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាកវិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាច*

*ធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាល បានអញ្ជើញឱ្យចូលរួម ។"*

នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលព័ត៌មានពីភាគីកម្មករនិយោជិត និង និយោជកថា ភាគីកម្មករនិយោជិត នៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ព្រោះនិយោជក មិនអនុញ្ញាតិឱ្យថ្នាក់ដឹកនាំសហជីព ៣នាក់ចូលធ្វើការវិញ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានបង្គាប់ឱ្យលេខាធិការដ្ឋានអញ្ជើញភាគីទាំងសងខាង មកចូលរួមកិច្ចប្រជុំមុនសវនាការ ក្នុងគោលបំណងដើម្បីសាកសួរព័ត៌មានពីភាគីទាំងសងខាងអំពីស្ថានភាពកូដកម្ម ឬឡុកអៅ ដែលកំពុងកើតឡើង និង ដើម្បីបញ្ជាក់ឱ្យភាគីទាំងសងខាងផ្អាកនូវរាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ដើម្បីឱ្យនីតិវិធីអាជ្ញាកណ្ដាលអាចដំណើរការដោះស្រាយវិវាទការងារក្នុងសំណុំរឿងនេះបាន។

មន្ត្រីលេខាធិការដ្ឋានបានទាក់ទងទៅភាគីសហជីព ហើយបានទទួលព័ត៌មានថា ភាគីសហជីពមិនចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ដោយលើកហេតុផលថាការធ្វើដំណើរពី ខេត្តកំពង់ស្ពឺ មកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅភ្នំពេញឆ្ងាយពេក ហើយត្រូវចំណាយច្រើនចំពោះការធ្វើដំណើរ និង បន្ថែមពីនេះទៀតក្រុមប្រឹក្សាអាជ្ញាកណ្ដាលគ្មានអំណាចក្នុងការបញ្ជាឱ្យក្រុមហ៊ុនអនុញ្ញាតិឱ្យកម្មករទាំងអស់ចូលធ្វើការទេ។ ភាគីសហជីពក៏បានបញ្ជាក់ថា សហជីពបានមកចូលរួមកិច្ចប្រជុំមុនសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿង លេខ ០២/០៨ -ខេមបូឌា អ៊ីបភែរ៉េល ថ្មីៗនេះរួចមកហើយ ដូច្នេះ ទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច សំណុំរឿងលេខ០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល តាមនីតិវិធីចុះ។ នៅថ្ងៃជួបប្រជុំមុនសវនាការនៅ ព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ភាគីនិយោជកមានវត្តមាននៅក្នុងការជួបប្រជុំនេះ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងការប្រជុំនេះទេ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ មិនបានគោរពទៅតាមប្រការ២០ នៃប្រកាសលេខ០៩៩ ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលខាងលើ ដោយមិនបានផ្អាកនូវវិធានការកូដកម្មរបស់ខ្លួនក្នុងកំឡុងពេលដំណើរការរបស់ក្រុមអាជ្ញាកណ្ដាលឡើយ ហើយក៏មិនបានចូលរួមក្នុងកិច្ចប្រជុំមុនសវនាការតាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលទៀត។

បន្ថែមលើនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយប្រការ២០ នៃប្រកាសលេខ០៩៩ ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលខាងលើថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាភាគីកម្មករកំពុងធ្វើកូដកម្ម ឬភាគីនិយោជកធ្វើឡុកអៅ។

THE ARBITRATION COUNCIL

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះបានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗដូចខាងក្រោមៈ

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះចែងថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីព កម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ។"*

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និងសំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ផ្អែកលើការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាភាគីសហជីព ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយ ថាមានបំណងយកវិវាទការងារនេះមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ព្រោះភាគីសហជីពនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលនីតិវិធីរបស់ក្រុមអាជ្ញាកណ្តាល និង មិនចូលរួមក្នុងកិច្ចប្រជុំមុនសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីស្វែងរកដំណោះស្រាយលើវិវាទការងារដោយសុទ្ធចិត្តក្នុង សំណុំរឿងនេះទេ។

ម្យ៉ាងវិញទៀត ទាក់ទងនឹងការការធ្វើឡុកអៅរបស់និយោជកនៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿង លេខ២២/០៧-ផាកវីយូ ដែលក្នុងសំណុំរឿងនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់បិទសំណុំរឿងនោះ ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ហើយនិយោជកនៅតែឡុកអៅ ក្នុងកំឡុងពេល ដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សា អាជ្ញាកណ្តាល ។

ផ្អែកលើការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាភាគីទាំងពីរ ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ពួកគេមានបំណងយកវិវាទការងារនេះមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយនៅក្នុងស្ថានភាពបែបនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏មិនអាចបន្តនីតិវិធីអាជ្ញាកណ្តាលតទៅទៀតបានដែរ ព្រោះភាគីទាំងពីរបានប្រកាន់យកគោលជំហរៀងៗខ្លួនហើយមិនសហការគ្នាក្នុងការដោះស្រាយវិវាទការងារនេះ។ ហេតុដូច្នេះ ដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុង

សំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុង សំណុំរឿងលេខ០៤/០៨-ខេមបូឌា អ៊ីបភែរ៉េល នេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

**សម្រេច**

- មិនបន្តដំណើរការអាជ្ញាកណ្តាល ក្នុងសំណុំរឿងលេខ ០៤/០៨-ខេមបូឌា អាភែរ៉េល នេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុំ សុន្ធី**

ហត្ថលេខា: -----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ស៊ុន គឹមស៊ាន**

ហត្ថលេខា: -----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: -----------------------------------

THE ARBITRATION COUNCIL